002/19-09-2007-ECCC/TC
**E1/349**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 09 / 2015
ម៉ោង (Time/Heure) : 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# **<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**
# **<u>សាធារណៈ</u>**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ព្រហស្បតិ៍ ទី១៧ ខែ កញ្ញា ឆ្នាំ ២០១៥

## **សវនាការលើភស្តុតាង - ថ្ងៃ ៣៣០**

**រៀបចំដោយ៖ ជា ស៊ីវហ៊ង និង Maddalena GHEZZI**

| |
|---|
| <u>**កំណត់ហេតុអ្នកចូលរួម**</u> |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ , ចៅក្រម Jean-Marc LAVERGNE , ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ង, លោកស្រី Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicolas KOUMJIAN, លោក សេង លាង, លោក Vincent de WILDE d'ESTMAEL, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អារុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក ឡោ ជុនធី, លោក វ៉ែន ពៅ |
| សាក្សី/ដើមបណ្ដឹង៖ ហ៊ឹម ម៉ាន (2-TCCP-252) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, កញ្ញា Kerri MILES, លោក ឡុង ង៉ែត, លោក គ្រី តុងហួ, កញ្ញា ស៊ឹម សុខជា, កញ្ញា Clementine PLAGNOL |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០៣ | បញ្ចប់ម៉ោង៖ ១៥.០៦ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.០៤ | បញ្ចប់ម៉ោង៖ ១០.៣៣ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣២ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៣៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៣ | ០៩.០៥ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៥ | ០៩.០៦ |
| ការដាក់សារណារបស់មេធាវីការពារក្ដី នួន ជា ទាក់ទងនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា សុំឲ្យកោះហៅសាក្សីបន្ថែម (E366) | មេធាវីការពារក្ដី នួន ជា<br><br><br>មេធាវីការពារក្ដី ខៀវ សំផន<br><br>អង្គជំនុំជម្រះ | ០៩.០៧<br>០៩.៣២<br>០៩.៥៨<br>០៩.២៥<br>០៩.៣៥<br>០៩.២៨<br>០៩.៣៣<br>១០.៣៣ | ០៩.២៥<br>០៩.៣៣<br>១០.០២<br>០៩.២៨<br>០៩.៤០<br>០៩.៣២<br>០៩.៣៤<br>១០.៣៥ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា | ០៩.៤១<br>១០.០២ | ០៩.៥២<br>១០.០៣ |
| | សហមេធាវីនាំមុខ | ០៩.៥២ | ០៩.៥៨ |
| ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន (2-TCCP-252) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា | ១០.៣៨<br>១០.៤២<br>១៤.២១ | ១០.៤២<br>១៤.២១<br>១៥.០៣ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគីប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគី ទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការដាក់សារណារបស់មេធាវីការពារក្ដី នួន ជា ទាក់ទងនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅសាក្សីបន្ថែម (E366)</u>**

មេធាវីការពារក្ដី នួន ជា បានស្នើសុំការបំភ្លឺពីសហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិអំពីមូលហេតុដែលសំណើសុំកោះហៅថាសាក្សីបន្ថែម (ឯកសារ E366) ត្រូវបានចុះហត្ថលេខាដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់។ មេធាវីការពារក្ដី នួន ជា ក៏បានបន្ថែមថាខ្លួនមិនអាចអាននិងពិនិត្យមើលឯកសារទាំងអស់ដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ នោះទេ។ ហេតុដូច្នេះមេធាវីការពារក្ដីបានស្នើសុំឱ្យមាន ធនធានបន្ថែមជាបន្ទាន់ ឬ ការផ្អាកសវនាការស្ដាប់សក្ខីកម្មពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិចាម។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានលើកឡើងពីបញ្ហានៃពេលវេលានិងបញ្ហាធនធាន ចាំបាច់ក្នុងការពិនិត្យមើលឯកសារទាំងនោះ និងបានរំលឹកពីសំណើរបស់ខ្លួនពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា ដោយសារតែកិច្ច

ស៊ើបអង្កេតកំពុងតែដំណើការ ដូច្នេះហើយខ្លួននឹងបន្តក្នុងការដាក់បង្ហាញឯកសារ។ ទោះយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិ មិនជំទាស់ទៅនឹងការស្នើសុំពេលវេលាបន្ថែមរបស់មេធាវីការពារក្តីនោះទេ ប្រសិនបើមានសំណើដែលសមហេតុផល។

អង្គជំនុំជម្រះបានសម្រេចថា បន្ទាប់ពីការតាំងសំណួរដើមបណ្តឹងរដ្ឋប្បវេណី (2-TCCP-252) ដោយសហមេធាវីនាំមុខ និងសហព្រះរាជអាជ្ញាបញ្ចប់ សវនាការនឹងត្រូវផ្អាកមួយសប្តាហ៍ ចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥។ សវនាការនឹងបន្តនៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ដោយឲ្យក្រុមមេធាវីការពារក្តី ធ្វើការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន (2-TCCP-252) ។

<u>ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន (2-TCCP-252)</u>

អង្គជំនុំជម្រះ សហមេធាវីនាំមុខ និងសហព្រះរាជអាជ្ញា បានធ្វើការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន (2-TCCP-252) ។

<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4706 | D22/164 | 00369046-00369058; 00417857-00417868; 00898349-00898349 | Civil Party Application of Mr. HIM Man | P | 00369050 00369051 | 00417861 00417868 | 00898349 |
| E3/5203 | D125/97 | 00218490-00218494; 00242089-00242092; 00321724-00321730 | Written Record of Interview of HIM Man | P | 00218492 | 00242091 | 00321726 |
| E3/9336 | D125/97.1 | 00218495-00218499; 00218500-00218504; 00286655-00286657 | Annex 1: Interview of HIM Man in "The Cham Rebellion, Survivors' Stories from the Villages", Ysa Osman, Documentation series No. 9, DC-Cam, 2006 | P | 00218496 00218497 | 00218503 | 00286655 00286656 |
| E3/5302 | D196.7 | 00635171-00635180; 00210484-00210490; 00623189-00623193 | Interview of Witness SENG Srun | P | 00635176 | 00210488 | 00623191 |

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5257 | D166/42 | 00243099-00243109; 00251012-00251022; 00342661-00342675 | Written Record of Interview of TAY Kimhuon | P | 00243107 00243108 | 00251021 | 00342673 |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩:០៥)
- សម្រេចផ្អាកកិច្ចដំណើការនីតិវិធីសវនាការមួយសប្ដាហ៍ ចាប់ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ បន្ទាប់ពីការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន (2-TCCP-252) ដោយសហមេធាវីនាំមុខ និងសហព្រះរាជអាជ្ញា និងឱ្យក្រុមមេធាវីការពារក្ដីតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន (2-TCCP-252) នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥។ (១៣.៣១)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផនទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥។ (១៥.០៦)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីទហ៊ង Maddalena GHEZZI